# I- ព្រះរាជក្រម

## ព្រះរាជក្រម នស/រកម/០៧០០/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការធានារ៉ាប់រង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

www.pheakdeylaw.com

# ច្បាប់
# ស្តីពី
# ការធានារ៉ាប់រង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងកិច្ចប្រតិបត្តិការធានារ៉ាប់រងការពារសិទ្ធិត្រឹមត្រូវរបស់ភាគីនានាចំពោះការធានារ៉ាប់រង ពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង និង រួមចំណែកកក្រើកកិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រង ។

**មាត្រា ២.-**

ច្បាប់នេះអនុវត្តចំពោះសកម្មភាពធានារ៉ាប់រងទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ការធានារ៉ាប់រងដែលប្រើនៅក្នុងច្បាប់នេះ គឺសំដៅលើការធ្វើកិច្ចសន្យាពាណិជ្ជកម្មធានារ៉ាប់រងមួយ ដែលក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភរ៉ាប់រងទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺឬក៏នៅពេលដែលបុគ្គលនោះឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង ។

**មាត្រា ៤.-**

អាចប្រកបអាជីវកម្មធានារ៉ាប់រងបាន គឺក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ។

**មាត្រា ៥.-**

ក្នុងកិច្ចប្រតិបត្តិការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង ត្រូវគោរពតាមគោលការណ៍ប្រកួតប្រជែងត្រឹមត្រូវដោយ អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

www.pheakdeylaw.com

មាត្រា ៦.-

រូបវន្តបុគ្គលនិងនីតិបុគ្គលដែលទទួលអាណត្តិធ្វើសកម្មភាពធានារ៉ាប់រង ត្រូវគោរពបទប្បញ្ញត្តិនិងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៧.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវគ្រប់គ្រងនិងត្រួតពិនិត្យលើអាជីវកម្មធានារ៉ាប់រងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**ជំពូកទី ២**

**កិច្ចសន្យាធានារ៉ាប់រង**

**ផ្នែកទី ១**

**មែបបទទូទៅ**

មាត្រា ៨.-

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់រងចំពោះហានិភ័យទាំងឡាយ ទោះជាអាយុជីវិត ឬមិនមែនអាយុជីវិតត្រូវចុះកិច្ចសន្យាធានារ៉ាប់រងតែជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាប័ណ្ណឲ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩.-

កិច្ចសន្យាធានារ៉ាប់រងជាភាសាខ្មែរ គឺជាការព្រមព្រៀងមួយដែលចែងអំពីទំនាក់ទំនងរវាងសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង និងអ្នកធានារ៉ាប់រង ។

អ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដែលចុះកិច្ចសន្យាជាមួយអ្នកធានារ៉ាប់រងហើយមានកាតព្វកិច្ចបង់បុព្វលាភរ៉ាប់រង ។

អ្នកធានារ៉ាប់រងគឺជាក្រុមហ៊ុនធានារ៉ាប់រងដែលចុះកិច្ចសន្យាជាមួយអ្នកត្រូវបានធានារ៉ាប់រងហើយមានកាតព្វកិច្ចធ្វើសំណងទាំងឡាយ និង/ឬបង់នូវផលប្រយោជន៍ទាំងឡាយ ។

មាត្រា ១០.-

ក្នុងការធ្វើកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ត្រូវគោរពតាមគោលការណ៍ស្មោះត្រង់មានផលប្រយោជន៍ទៅវិញទៅមកមានការស្រុះស្រួលគ្នាដោយឆ្លងតាមការចរចានិងមិនធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈឡើយ ។

មាត្រា ១១.-

ក្នុងការអនុវត្តន៍កិច្ចសន្យាធានារ៉ាប់រង ភាគីនីមួយៗមានសិទ្ធិបញ្ឈប់កិច្ចសន្យាមុនកាលកំណត់ ដោយការជូនដំណឹងជាមុនតាមរយៈលិខិតអនុសិដ្ឋ ឬតាមរយៈលិខិតជូនដំណឹងដែលមានបញ្ជាក់ការទទួលច្បាស់លាស់ ។

www.pheakdeylaw.com

មាត្រា ១២.-

នៅពេលដែលរូបវ័ន្តបុគ្គលឬនីតិបុគ្គលធ្វើសំណើសុំការធានារ៉ាប់រងហើយ ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមទទួលសំណើព្រមទាំងបានឯកភាពលើល័ក្ខខ័ណ្ឌផ្សេងៗ នៃកិច្ចសន្យាហើយនោះ កិច្ចសន្យាធានារ៉ាប់រងអាចចាត់ទុកថាបានព្រមព្រៀងគ្នារួចហើយ ។ បន្ទាប់មក ក្រុមហ៊ុនធានារ៉ាប់រងត្រូវចេញប័ណ្ណសន្យារ៉ាប់រងដែលភ្ជាប់នឹងវិញ្ញាបនប័ត្រធានារ៉ាប់រងទៅឲ្យអ្នកស្នើសុំធានារ៉ាប់រង ។ ប័ណ្ណសន្យារ៉ាប់រងដែលភ្ជាប់នឹងវិញ្ញាបនប័ត្រធានារ៉ាប់រងត្រូវមានចែង និងកំណត់ខ្លឹមសារសំខាន់ជាទូទៅដែលបានព្រមព្រៀងជាមុនរវាងភាគីទាំងពីរ ។

មាត្រា ១៣.-

វិញ្ញាបនប័ត្រធានារ៉ាប់រងត្រូវបានបញ្ជាក់ :

១- គោត្តនាមនិងនាមនិងអាស័យដ្ឋានរបស់ភាគីនៃកិច្ចសន្យា

២- បុគ្គលឬវត្ថុត្រូវបានធានារ៉ាប់រង

៣- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង

៤- ពេលវេលាចាប់ផ្តើមនិងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង

៥- ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង

៦- បុព្វលាភរ៉ាប់រងត្រូវបង់និងរបៀបបង់បុព្វលាភរ៉ាប់រង

៧- របៀបនិងល័ក្ខខ័ណ្ឌមួយចំនួននៃសេចក្តីប្រកាសគ្រោះថ្នាក់

៨- រយៈពេលនៃកិច្ចសន្យានិងរយៈពេលនៃការធានារ៉ាប់រង

៩- ល័ក្ខខ័ណ្ឌទាំងឡាយដែលកំណត់មោឃភាព និងការបាត់បង់សិទ្ធិព្រមទាំងល័ក្ខខ័ណ្ឌដែលអនុញ្ញាតដល់ភាគីនីមួយៗបញ្ឈប់កិច្ចសន្យាបានមុនកាលកំណត់ ។

មាត្រា ១៤.-

មានតែប័ណ្ណសន្យារ៉ាប់រង ឬកំណត់សំអាងទេដែលកត់ត្រាការធានាទៅវិញទៅមក រវាងក្រុមហ៊ុនធានារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រង ។ រីឯពាក្យស្នើសុំធានារ៉ាប់រងមិនមានតំលៃធានាដល់ភាគីទាំងពីរទេ ។

សំណើសុំបន្ត កែប្រែឬដាក់ឲ្យចូលជាធរមានឡើងវិញនូវកិច្ចសន្យាធានារ៉ាប់រងមួយដែលបានព្យួរទុកត្រូវបានចាត់ថាយល់ព្រម ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមិនបដិសេធនូវសំណើនោះក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ។

មាត្រា ១៥.-

រយៈពេលនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់នៅក្នុងប័ណ្ណសន្យារ៉ាប់រង ។ រាល់ការបន្ថែមឬកែប្រែលើប័ណ្ណសន្យាដើមត្រូវធ្វើឡើងដោយកិច្ចសន្យាបន្ថែម និងត្រូវមានចុះហត្ថលេខារបស់ភាគីទាំងសងខាង ។

www.pheakdeylaw.com

មាត្រា ១៦.-

អ្នកត្រូវបានធានារ៉ាប់រងត្រូវមានផលប្រយោជន៍ពីការធានារ៉ាប់រងដែលស្ថិតក្នុងកម្មវត្ថុត្រូវបានធានារ៉ាប់រង ។

ផលប្រយោជន៍ពីការធានារ៉ាប់រងមានន័យថា អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិក្នុងការទទួលយកផលប្រយោជន៍ដែលស្ថិតក្នុងកម្មវត្ថុត្រូវបានធានារ៉ាប់រង ។

កម្មវត្ថុត្រូវបានធានារ៉ាប់រងមានន័យថា ទ្រព្យសម្បត្តិផលឬប្រយោជន៍អ្វីមួយដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ អាយុជីវិតឬរូបរាងកាយរបស់ជនណាមួយ ។

មាត្រា ១៧.-

បន្ទាប់ពីបានធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវធានារ៉ាប់រងត្រូវបង់បុព្វលាភរ៉ាប់រងដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យា ។

ការធានារ៉ាប់រងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភរ៉ាប់រងតាមការកំណត់ក្នុងកិច្ចសន្យា ។

មាត្រា ១៨.-

ក្នុងករណីដែលពុំបានបង់បុព្វលាភរ៉ាប់រងណាមួយតាមកាលកំណត់នោះសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងមិនអាចព្យួរទុកឲ្យហួសពីរយៈពេល៣០ (សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចសន្យាធានារ៉ាប់រងឡើយ ។ ២០ (ម្ភៃ) ថ្ងៃក្រោយពីការចុះកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងដោយលិខិតអនុសិដ្ឋ ឬដោយលិខិតដែលមានបញ្ជាក់ការទទួលច្បាស់លាស់ដល់អ្នកត្រូវបានធានារ៉ាប់រងឬជនដែលមានភារកិច្ចបង់បុព្វលាភរ៉ាប់រងឲ្យយកបុព្វលាភរ៉ាប់រងមកបង់នៅទីកន្លែងដែលបានព្រមព្រៀងគ្នា ។ ក្រោយពីបានទទួលដំណឹងរួចហើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងនៅតែមិនមកបង់បុព្វលាភរ៉ាប់រងក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នោះក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិលុបកិច្ចសន្យាចោល ។

មាត្រា ១៩.-

ការបាត់បង់ឬការខូចខាតទាំងឡាយបណ្តាលមកពីហានិភ័យដែលមានចែងក្នុងប័ណ្ណសន្យារ៉ាប់រងត្រូវស្ថិតនៅក្នុងបន្ទុកធ្វើសំណងរបស់ក្រុមហ៊ុនធានារ៉ាប់រង ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើសំណងចំពោះការបាត់បង់ ឬការខូចខាតទាំងឡាយដែលបណ្តាលមកពីកំហុសដោយចេតនា ឬដោយបន្លំបោកប្រាស់របស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ។

ក្រុមហ៊ុនធានារ៉ាប់រងធានាផងដែរចំពោះការបាត់បង់និងការខូចខាតបង្កឡើងដោយបុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងទោះជាប្រភេទនិងភាពធ្ងន់ធ្ងរនៃកំហុសទាំងនោះបែបណាក៏ដោយ ។

www.pheakdeylaw.com

**មាត្រា ២០.-**

កិច្ចសន្យាធានារ៉ាប់រងមួយចាត់ទុកជាមោឃៈ នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញថា អ្នកត្រូវបានធានារ៉ាប់រងមានការលាក់លៀម ឬធ្វើប្រតិវេទន៍ខុសដោយចេតនាហើយបណ្តាលឲ្យមានការប្តូរកម្មវត្ថុនៃហានិភ័យ ។

ការភ្លេចភ្លាំង ឬការធ្វើប្រតិវេទន៍មិនច្បាស់លាស់របស់អ្នកត្រូវបានធានារ៉ាប់រងដោយចេតនានឹងមិននាំទៅដល់ មោឃភាពនៃការធានារ៉ាប់រង ។

**មាត្រា ២១.-**

ប្រសិនបើគ្រោះភ័យបានកើតឡើងដោយអំពើចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង ទោះបីក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយក្តី ឬមិនទាន់បានធ្វើសំណងក្តី ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងបានរកឃើញនូវអំពើបែបនេះ ឬការប្រឌិតនូវគ្រោះថ្នាក់ដោយមានភស្តុតាងច្បាស់លាស់នោះ ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិប្តឹងទៅតុលាការដើម្បីសុំបដិសេធការទទួលខុសត្រូវឬទារសំណងមកវិញ ។

**មាត្រា ២២.-**

រាល់ចំណុចពាក់ព័ន្ធនឹងសិទ្ធិណាមួយរបស់អ្នកត្រូវបានធានារ៉ាប់រងដែលមានចែងក្នុងល័ក្ខខ័ណ្ឌទូទៅនៃប័ណ្ណសន្យារ៉ាប់រង នឹងត្រូវចាត់ទុកជាមោឃៈនៅពេលដែលអាជ្ញាកណ្តាលបញ្ជាក់ថា អ្នកត្រូវបានធានារ៉ាប់រងមានកំហុសហើយសាមីខ្លួនទទួលស្គាល់ ។

**មាត្រា ២៣.-**

ក្នុងប្រភេទធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបានបង្កឲ្យមានការខូចខាតឬបាត់បង់ដល់តតិយជន ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងផ្ទាល់ទៅតតិយជនដែលរងគ្រោះនោះ ។

ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវគឺជាការធានារ៉ាប់រងមួយប្រភេទដែលក្នុងនោះការធ្វើសំណងផ្នែកភារៈទទួលខុសត្រូវ ត្រូវធ្វើដោយផ្ទាល់ទៅឲ្យតតិយជនដែលជាកម្មវត្ថុនៃការធានារ៉ាប់រង ។

**មាត្រា ២៤.-**

ក្នុងករណីធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមនៅតែទទួលខុសត្រូវដដែលចំពោះអ្នកត្រូវបានធានារ៉ាប់រង ។

ការធានារ៉ាប់រងបន្តគឺជាកិច្ចប្រតិបត្តិការធានារ៉ាប់រង ដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្តនូវហានិភ័យមួយផ្នែក ឬទាំងស្រុងដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង ។

www.pheakdeylaw.com

មាត្រា ២៥.-

បណ្ណ័សន្យាដែលពាក់ព័ន្ធនឹងកិច្ចធានារ៉ាប់រង ត្រូវមានកំណត់អាជ្ញាយុកាលក្នុងប័ណ្ណសន្យារ៉ាប់រង ។ ប៉ុន្តែអាជ្ញាយុកាលនេះមិនត្រូវលើសពី ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលមានគ្រោះភ័យកើតឡើង ។

អាជ្ញាយុកាលត្រូវបញ្ចប់ដោយការព្រមព្រៀងគ្នារវាងភាគីទាំងពីរ បន្ទាប់ពីមានការបញ្ជាក់របស់អ្នកត្រួតពិនិត្យដែលជាអាជ្ញាកណ្តាលក្រោយពីគ្រោះភ័យកើតឡើង ។

## ផ្នែកទី២

## ការធានារ៉ាប់រងទ្រព្យសម្បត្តិ

មាត្រា ២៦.-

ការធានារ៉ាប់រងទ្រព្យសម្បត្តិគឺជាកិច្ចសន្យាធ្វើសំណងមួយនៅពេលដែលមានគ្រោះភ័យកើតឡើង ។

សំណងដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រងទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងមិនអាចលើសពីតំលៃនៃវត្ថុបានធ្វើប្រតិវេទន៍នៅពេលចុះកិច្ចសន្យាធានារ៉ាប់រងឡើយ លើកលែងតែមានការព្រមព្រៀងគ្នាដោយឡែក ។

មាត្រា ២៧.-

ករណីមានការបាត់បង់ទាំងស្រុងនូវវត្ថុដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពីហេតុការណ៍ណាមួយដែលពុំបានគ្រោងទុកជាមុនក្នុងប័ណ្ណសន្យារ៉ាប់រងទេ ការធានារ៉ាប់រងត្រូវបញ្ចប់ដោយស្របច្បាប់ ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវសងទៅអ្នកត្រូវបានធានារ៉ាប់រងវិញចំនួន ៩០(កៅសិប)ភាគរយ នៃបុព្វលាភរ៉ាប់រងចំពោះរយៈពេលដែលនៅសល់ ។

មាត្រា ២៨.-

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងការប្តឹងតទល់ជាមួយតតិយជន ដែលបានបង្កឱ្យមានការខូចខាត ដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងសើរើនឹងបច្ចាញាតិ បុព្វជន ញាតិព័ន្ធ អ្នកគ្រប់គ្រងនិងនិយោជិតដែលរស់នៅធម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទេ លើកលែងតែក្នុងករណីព្យាបាទប្រព្រឹត្តដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ ។

## ផ្នែកទី ៣

## ការធានារ៉ាប់រងបុគ្គល

មាត្រា ២៩.-

ក្នុងការធានារ៉ាប់រងបុគ្គល ចំនួនទឹកប្រាក់ធានារ៉ាប់រងដែលបានកំណត់ក្នុងប័ណ្ណសន្យារ៉ាប់រងគឺជាកំរិតខ្ពស់បំផុតនៃចំនួនទឹកប្រាក់ដែលត្រូវសង ។



www.pheakdeylaw.com

ការធានារ៉ាប់រងបុគ្គលរួមមានការធានារ៉ាប់រងលើអាយុជីវិត និងការធានារ៉ាប់រងលើគ្រោះថ្នាក់ទាំងឡាយដល់រូបរាងកាយ ។

**មាត្រា ៣០.-**

ក្នុងការធានារ៉ាប់រងបុគ្គល ក្រោយពីបានធ្វើសំណងរួចហើយ ក្រុមហ៊ុនធានារ៉ាប់រងមិនអាចទាមទារការផ្ទេរសិទ្ធិពីភាគីជាប់កិច្ចសន្យា ឬអ្នកទទួលផលដើម្បីប្តឹងតទល់ជាមួយតតិយជនឡើយ ។

**មាត្រា ៣១.-**

បុគ្គលម្នាក់ៗអាចស្នើសុំការធានារ៉ាប់រងលើអាយុជីវិតរបស់ខ្លួន ឬរបស់តតិយជន កាលបើតតិយជននោះបានយល់ព្រមជាលាយលក្ខអក្សរបញ្ជាក់ច្បាស់ពីចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង ។

ការធានារ៉ាប់រងលើមរណភាពត្រូវបានហាមឃាត់ចំពោះ :

១- ជនមិនពេញលក្ខណៈខាងសតិ ។

២- ជនដែលកំពុងព្យាបាលនៅក្នុងមន្ទីរពេទ្យវិកលចរិត ។

**មាត្រា ៣២.-**

ក្រៅពីនិទ្ទេសចាំបាច់ក្នុងកិច្ចសន្យាធានារ៉ាប់រង បណ្ណសន្យារ៉ាប់រងលើអាយុជីវិតត្រូវបញ្ជាក់ដូចខាងក្រោមនេះ :

១- គោត្តនាម-នាមនិងថ្ងៃខែឆ្នាំកំណើតរបស់អ្នកដែលត្រូវចុះកិច្ចសន្យា ។

២- គោត្តនាមនិងនាមរបស់អ្នកទទួលផល ប្រសិនបើមាន ។

៣- ហេតុការណ៍ ឬការកំណត់ដែលត្រូវប្រគល់ឲ្យវិញនូវទឹកប្រាក់ធានារ៉ាប់រង ។

៤- លក្ខខណ្ឌនៃការបន្ធូរបន្ថយ បើសិនជាមានចែងនៅក្នុងកិច្ចសន្យា ។

**មាត្រា ៣៣.-**

ការធានារ៉ាប់រងលើមរណភាពត្រូវចាត់ទុកថាគ្មានប្រសិទ្ធិភាព ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងធ្វើអត្តឃាត ។

**មាត្រា ៣៤.-**

កិច្ចសន្យាធានារ៉ាប់រងលែងមានប្រសិទ្ធភាពចំពោះអ្នកទទួលផល នៅពេលដែលអ្នកទទួលផលនោះបានសំលាប់ ឬសមគំនិតសំលាប់អ្នកត្រូវបានធានារ៉ាប់រងដោយចេតនា ។

**មាត្រា ៣៥.-**

វិវាទរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងដែលពុំអាចដោះស្រាយបានដោយការសំរុះសំរួលគ្នា ឬតាមរយៈអាជ្ញាកណ្តាលទេនោះ ភាគីទាំងពីរអាចប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

www.pheakdeylaw.com

## ជំពូកទី ៣
## ប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច
### ផ្នែកទី ១
### ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន

**មាត្រា ៣៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គលជាម្ចាស់យានយន្តដែលប្រកបអាជីវកម្មយកកំរៃតាមផ្លូវគោកនានាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវចំពោះរាល់ការខូចខាតដែលបណ្តាលមកពីសកម្មភាពនៃយានយន្តរបស់ខ្លួន រួមទាំងរ៉ឺម៉កសណ្តោងគ្រប់ប្រភេទបង្កឡើងដល់តតិយជន ។

ការធានារ៉ាប់រងនេះមិនត្រឹមតែមានប្រសិទ្ធភាពចំពោះម្ចាស់យានយន្តប៉ុណ្ណោះទេប៉ុន្តែត្រូវមានប្រសិទ្ធភាពផងដែរចំពោះអ្នកបើកបរនិងអ្នកកាន់កាប់ថែទាំយានយន្ត ។

ប្រភេទយានយន្តប្រកបអាជីវកម្មទាំងឡាយដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៧.-**

តតិយជនទាំងឡាយដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ចរាចរណ៍ ហើយបានទទួលរងគ្រោះផលរំខានរាងកាយឬទ្រព្យសម្បត្តិដោយសារយានយន្តប្រកបអាជីវកម្មលើផ្លូវគោកបង្កឡើង សុទ្ធតែត្រូវបានក្រុមហ៊ុនធានារ៉ាប់រងធ្វើសំណងចំពោះរាល់ការខូចខាតអន្តរាយនោះឲ្យទាន់ពេលវេលា និងសមស្រុងទៅតាមកំរិតនៃការខូចខាត ។

**មាត្រា ៣៨.-**

ការធានារ៉ាប់រងតតិយជនមិនអនុវត្តចំពោះការខូចខាតបណ្តាលមកពីគ្រោះថ្នាក់ដែលកើត ឡើងនៅក្រៅភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែមានកិច្ចព្រមព្រៀងដោយ ឡែក ។

**មាត្រា ៣៩.-**

ការធានារ៉ាប់រងនេះអនុវត្តចំពោះជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរដែលបានទទួលរងរបួស ពិការ ឬមរណភាព ទោះបីជនទាំងនោះត្រូវបានដឹកជញ្ជូនក្នុងយានយន្តដែលត្រូវបានធានារ៉ាប់រងក៏ដោយ ។

### ផ្នែកទី ២
### ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

**មាត្រា ៤០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយដែលជាម្ចាស់ការដ្ឋាន ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ។

នៅពេលបើកការដ្ឋាន បុគ្គលទាំងនោះត្រូវបញ្ជាក់ថា ខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ។

ប្រភេទការដ្ឋានដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤១.-

កិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវ ដែលធ្វើឡើងស្របតាមមាត្រា ៤០ នៃច្បាប់នេះត្រូវមានល័ក្ខខ័ណ្ឌទាំងឡាយស្តីពីការធានារ៉ាប់រងសំរាប់រយៈពេលបន្ទាប់ពីការបញ្ចប់ការដ្ឋាន ។

**ផ្នែកទី ៣**

**ការធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ**

មាត្រា ៤២.-

រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមមធ្យោបានដឹកជញ្ជូននានា ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវចំពោះអ្នកដំណើរដែលជិះតាមមធ្យោបានដឹកជញ្ជូនរបស់ខ្លួន ទោះបីមធ្យោបាយដឹកជញ្ជូនទាំងនោះចរាចរលើផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ឬផ្លូវដែកក៏ដោយ ។

ប្រភេទមធ្យោបាយដឹកជញ្ជូនអ្នកដំណើរដែលត្រូវមានការធានារ៉ាប់រងត្រូវកំណត់ដោយអនុក្រឹត្យ ។

**ជំពូកទី ៤**

**ក្រុមហ៊ុនធានារ៉ាប់រងនិងការត្រួតពិនិត្យរបស់រដ្ឋ**

**ផ្នែកទី ១**

**ក្រុមហ៊ុនធានារ៉ាប់រង**

មាត្រា ៤៣.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវមានចុះបញ្ជីពាណិជ្ជកម្ម ហើយស្ថិតនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៤.-

ក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្រគល់អំណាចដឹកនាំ ចាត់ចែង ឬទាត់ឲ្យដល់បុគ្គលទាំងឡាយណាដែលធ្លាប់មានទោសណាមួយដូចជា : បទល្មើសចោរកម្ម បទល្មើសរំលោភសេចក្តីទុកចិត្ត បទល្មើសចេញមូលប្បទានប័ត្រគ្មានសវិធានវត្ថុដោយចេតនា បទល្មើសប៉ះពាល់ដល់ឥណទានរដ្ឋ បទល្មើសឆបោក ឬអំពើនៃការលាក់វត្ថុដែលបានមកពីការប្រព្រឹត្តិបទល្មើស ។

រាល់ការផ្តន្ទាសទោសដោយការប៉ុនប៉ងឬការសមគំនិតក្នុងការប្រព្រឹត្តិបទល្មើសដូចខាងលើនេះ ឬមួយរាល់ការផ្តន្ទាទោសជាប់ពន្ធនាគារមួយឆ្នាំយ៉ាងតិចទោះបីជាប្រភេទបទល្មើសណាក៏ដោយដែលបានប្រព្រឹត្ត គឺសុទ្ធតែផ្តល់នូវអសមត្ថភាពដូចគ្នា ។

www.pheakdeylaw.com

មាត្រា ៤៥.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ទោះជារបស់រដ្ឋក្តី ជារបស់ឯកជនក្តី ឬជាក្រុមហ៊ុនចំរុះក្តី អាចត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា តែក្នុងទ្រង់ទ្រាយជាក្រុមហ៊ុនភាគហ៊ុនប៉ុណ្ណោះ ។

មាត្រា ៤៦.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយអាចធ្វើប្រតិបត្តិការលើវិស័យធានារ៉ាប់រងបានតាមប្រភេទជា :

ក- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់រៀលយ៉ាងតិចបំផុតសមមូលនឹង ៥.០០០.០០០ (ប្រាំលាន) អេសឌីអ័រ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

ខ- ក្រុមហ៊ុនធានារ៉ាប់រងទូទៅដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់រៀលយ៉ាងតិចបំផុតសមមូលនឹង ៥.០០០.០០០ (ប្រាំលាន) អេសឌីអ័រ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

គ- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនិងទូទៅដែលត្រូវមានដើមទុនចុះបញ្ជីជាប្រាក់រៀលយ៉ាងតិចបំផុតសមមូលនឹង ១០.០០០.០០០ (ដប់លាន) អេសឌីអ័រ តាមអត្រាពេលចេញអាជ្ញាប័ណ្ណ ។

មាត្រា ៤៧.-

ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់មិនអាចធ្វើអាជីវកម្មនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានទេ បើសិនជាក្រុមហ៊ុននោះ :

ក-មិនមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច

ខ-មិនបានចុះបញ្ជីសំរាប់ប្រភេទណាមួយដូចមានចែងក្នុងមាត្រា ៤៦ នៃច្បាប់នេះ ។

មាត្រា ៤៨.-

មុននឹងចាប់ផ្តើមដំណើរការអាជីវកម្ម ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលមានការអនុញ្ញាតរួចហើយត្រូវបំពេញបែបបទដូចខាងក្រោមនេះនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ :

-ផ្តល់លិខិតឬឯកសារដែលបញ្ជាក់អះអាងថាបានដាក់ប្រាក់តំកល់ចំនួនស្មើនឹង ១០(ដប់) ភាគរយនៃដើមទុននៅធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជារួចហើយ ។ ប្រាក់តំកល់នេះត្រូវបានរក្សាទុករហូតដល់ពេលដែលក្រុមហ៊ុនបញ្ឈប់សកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ។

-ផ្តល់លិខិត ឬឯកសារដែលបញ្ជាក់អះអាងថា បានរក្សាទុកទឹកប្រាក់ជាកំរិតសាធនភាពនៅធនាគារណាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិ ។ កំរិតសាធនភាពនេះត្រូវបានកំណត់ទៅតាមប្រភេទក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ។ ប៉ុន្តែកំរិតជាអប្បបរមានៃសាធនភាពមិនទាបជាង ៥០(ហាសិប) ភាគរយនៃដើមទុនចុះបញ្ជីឡើយ ។

www.pheakdeylaw.com

## ផ្នែកទី ២
## ការត្រួតពិនិត្យរបស់រដ្ឋ

មាត្រា ៤៩.-

ការត្រួតពិនិត្យរបស់រដ្ឋធ្វើឡើងដើម្បីផលប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង អ្នកចុះកិច្ចសន្យា និងអ្នកទទួលផលនៃកិច្ចសន្យាធានារ៉ាប់រង និងដើម្បីផលប្រយោជន៍នៃមូលធនកម្ម ។

ចំពោះក្រុមហ៊ុនរដ្ឋនិងក្រុមហ៊ុនចំរុះដែលមានភាគកម្មយ៉ាងតិច ៥១ (ហាសិបមួយ) ភាគរយជារបស់រដ្ឋ ត្រូវអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

ចំពោះក្រុមហ៊ុនឯកជនត្រូវអនុវត្តតាមអាជ្ញាប័ណ្ណដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## ភ្នាក់ងារធានារ៉ាប់រងនិងជើងសាធានារ៉ាប់រង

មាត្រា ៥០.-

ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលកំរៃពីក្រុមហ៊ុនធានារ៉ាប់រងនិងកាន់កាប់អាជីវកម្មធានារ៉ាប់រង ជួសមុខឲ្យក្រុមហ៊ុនធានារ៉ាប់រងក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ច្បាស់លាស់ ។

ជើងសាធានារ៉ាប់រងជានីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្តល់នូវសេវាជាអ្នកកណ្តាលរវាងអ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដើម្បីសំរេចនូវកិច្ចសន្យាធានារ៉ាប់រងណាមួយ និងប្រមូលកំរៃជើងសាស្របច្បាប់ ។

មាត្រា ៥១.-

របៀបបទនៃការរៀបចំនិងការប្រព្រឹត្តិទៅនៃភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងព្រមទាំងលក្ខខ័ណ្ឌផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥២.-

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៦ មាត្រា ៤០ ឬមាត្រា ៤២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល ទៅ ១.៥០០.០០០ (មួយលានប្រាំសែន) រៀល និងតំរូវឲ្យមានការធានារ៉ាប់រង ។ ការអនុគ្រោះដែលទាក់ទងក្នុងការអនុវត្តន៍ជាក់ស្តែងនៃវាក្យខ័ណ្ឌខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យដោយអនុលោមទៅតាមប្រភេទយានយន្ត និងប្រភេទការដ្ឋាននីមួយៗ ។

មាត្រា ៥៣.-

ការប្រព្រឹត្តិល្មើសនឹងមាត្រា ៤៥ ឬមាត្រា ៤៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ៥០.០០០.០០០ (ហាសិបលាន) រៀល និងត្រូវដកហូតអាជ្ញាប័ណ្ណមកវិញ ។

www.pheakdeylaw.com

មាត្រា ៥៤.-

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ។

ក្នុងករណីដែលជនទាំងនោះនៅតែបន្តប្រព្រឹត្តបទល្មើសដោយពុំរាងចាលនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

មាត្រា ៥៥.-

ចំពោះបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដូចមានចែងក្នុងមាត្រា ៥០ នៃច្បាប់នេះ ត្រូវមានការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងណាមួយយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ចំពោះបុគ្គលទាំងឡាយដែលប្រកបអាជីវកម្មដូចមានចែងក្នុងមាត្រា ៣៦ និងមាត្រា ៥២ នៃច្បាប់នេះ ត្រូវមានការធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងណាមួយយ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

ផុតរយៈពេលកំណត់ទាំងពីរនេះត្រូវអនុវត្តទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៥៦.-**

**បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។**

**រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ　　ព្រះហស្តលេខា

សូមឡាយព្រះហស្តលេខា　　**នរោត្តម សីហនុ**

នាយករដ្ឋមន្ត្រី　　បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ហត្ថលេខា　　ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហ៊ុន សែន**　　ហត្ថលេខា

**គាត ឈន់**

★★★